**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ /០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- យោងសេចក្តីសំរេចរបស់មហាសន្និបាត នៃអង្គការសហប្រជាជាតិលេខ ៥៧/១៦៤ ចុះថ្ងៃទី ១៨ ខែ ឆ្នាំ ២០០២
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤

## សម្រេច

មាត្រា ១ ._

ត្រូវបានបង្កើត **ទិវាអន្តរជាតិស្តីពីគ្រួសារ** ( International Day of Families ) នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី ១៥ ខែ ឧសភា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធពិធីនេះទូទាំងប្រទេស ក្នុងគោលបំណង និង ទិសដៅ ជំរុញ និង លើកទឹកចិត្តដល់សកម្មភាពពាក់ព័ន្ធនឹងគ្រួសារ ដែលជាផ្នែកមួយនៃកិច្ចអភិវឌ្ឍន៍នៃប្រទេសជាតិ និង សម្រេចឱ្យបាននូវវិធីដោះស្រាយមួយពេញលេញ និង ឯកភាពគ្នាចំពោះបញ្ហានានា ដែលពាក់ព័ន្ធនឹងគ្រួសារ ។

មាត្រា ២ ._

ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលសម្រេចប្រគល់ភារកិច្ចបន្ថែមជូន ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រៀបចំយន្តការសម្របសម្រួល ដែលមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ចូលរួមរៀបចំគោលនយោបាយ និង កម្មវិធីរបស់រាជរដ្ឋាភិបាលស្តីពីគ្រួសារ
- តាមដាន និង វាយតម្លៃកម្មវិធីនានា របស់អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ចំពោះបញ្ហាគ្រួសារ ដោយផ្សាភ្ជាប់ជាមួយនឹងទិវាអន្តរជាតិស្តីពីគ្រួសារ
- ផ្តល់នូវមធ្យោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញទិវាអន្តរជាតិស្តីពីគ្រួសារ នៅថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ
- រៀបចំលំអិត និង អនុវត្តកម្មវិធីថ្នាក់ជាតិ ដើម្បីរៀបចំការប្រារព្ធទិវាអន្តរជាតិស្តីពីគ្រួសារ ក្នុងទម្រង់ជារបៀបវារៈ សម្រាប់សកម្មភាពជាតិ
- ពិនិត្យឡើងវិញ និង វាយតម្លៃស្ថានភាពគ្រួសារ និង រកឱ្យឃើញនូវបញ្ហាជាក់លាក់
- បំផុសការយល់ដឹងរបស់សាធារណជនអំពីបញ្ហាពាក់ព័ន្ធគ្រួសារ និង ផ្តល់តួនាទីឈានមុខដល់ការសម្តែងអំពីបញ្ហាគ្រួសារ
- តាមដាន និង វាយតម្លៃការអនុវត្តកម្មវិធី និង គោលនយោបាយស្តីពីគ្រួសារ
- ជំរុញ និង ស្រាវជ្រាវអំពីបញ្ហាគ្រួសារ និង ធ្វើជាកន្លែងផ្ទុកទិន្នន័យ និង ព័ត៌មានជាតិពាក់ព័ន្ធនឹងបញ្ហាគ្រួសារ
- លើកទឹកចិត្តដល់ការដាក់បញ្ចូលកម្មវិធីគ្រួសារ ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍ និង ក្នុងកម្មវិធីអប់រំសិក្សាធិការជាតិ ។

មាត្រា ៣ ._

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវសហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ គ្រប់ក្រសួង ស្ថាប័នរដ្ឋ សាលាខេត្ត ក្រុង គ្រឹះស្ថានសិក្សា សហគ្រាសសាធារណៈ

សហគ្រាសឯកជន អង្គការក្រៅរដ្ឋាភិបាល សមាគម និង សហគមន៍ ដើម្បីចាត់ចែងរៀបចំប្រារព្ធពិធីទិវាអន្តរជាតិស្តីពីគ្រួសារ នៅថ្នាក់ជាតិ និង នៅថ្នាក់ខេត្ត ក្រុង ទូទាំងប្រទេស និង បំផុសចលនាចូលរួមរបស់មន្ត្រីរាជការ មន្ត្រីនគរបាល យោធិន កម្មករ និយោជិត សិស្ស និស្សិត និង ប្រជារាស្ត្រ ស្របតាមស្មារតីទិវាអន្តរជាតិស្តីពីគ្រួសារ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវសហការជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ រៀបចំសេចក្តីណែនាំអំពីការប្រារព្ធទិវាអន្តរជាតិស្តីពីគ្រួសារ និង ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលទិវាអន្តរជាតិស្តីពីគ្រួសារ ជូនរាជរដ្ឋាភិបាលរៀងរាល់ឆ្នាំ ។

**មាត្រា ៤ ..**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវលើកគម្រោងថវិកា ដែលស្ថិតក្នុងបន្ទុកផែនការចំណាយរបស់ក្រសួង សម្រាប់បំរើសកម្មភាពការងារ និងរៀបចំទិវាអន្តរជាតិស្តីពីគ្រួសារជារៀងរាល់ឆ្នាំ ។

**មាត្រា ៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ